មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
Cambodian Mine Action Centre

# របាយការណ៍

- ការអប់រំមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម
- ជួយជនរងគ្រោះដោយសារមីន
- និងអភិវឌ្ឍន៍ក្រោយបោសសំអាតមីន

ប្រចាំខែមករា ឆ្នាំ២០២០









## របាយការណ៍ស្តីអំពី
## ការងារអប់រំផ្សព្វផ្សាយយល់ដឹងពីមីន/សំណល់ជាតិផ្ទុះពីសង្រ្គាម
## ជួយជនរងគ្រោះដោយសារមីន និងអភិវឌ្ឍន៍ក្រោយបោសសំអាតមីនរួច
## ប្រចាំខែ មករា ឆ្នាំ២០២០

## ១-ស្ថានភាពទូទៅ:

ក្នុងខែមករានៃឆ្នាំ២០២០នេះ គឺជារដូវកាលបញ្ចប់នៃការប្រមូលភោគផលស្រូវ និងផលនេសាទផងដែរ ដោយឡែកតំបន់ខ្ពង់រាបចាប់ផ្តើមប្រមូលភោគផលចំការម្តង ដូចជាសណ្តែក ដំឡូងគ្រប់ប្រភេទជាដើម។ នៅពេលនេះ ប្រជាកសិករមួយចំនួន បានប្រើប្រាស់គ្រឿងចក្រធុនធ្ងន់ ដើម្បីប្រមូលផលកសិកម្ម មានម៉ាស៊ីនច្រូតកាត់ស្រូវ និងរថយន្ត ត្រាក់ទ័រ សម្រាប់ដឹកផលិតផលកសិកម្ម។ នៅតំបន់មួយចំនួន បន្ទាប់ពីបានប្រមូលភោគផលស្រូវស្រែរួច ពួកគេក៏ចាប់ផ្តើមគាស់ដំឡូងគ្រប់ប្រភេទ ពិសេសដំឡូងមី ដើម្បីលក់បន្តឱ្យឈ្មួញនាំចេញទៅក្រៅប្រទេស ដូចជានៅតំបន់ជួរព្រំដែនកម្ពុជា-ថៃ។ នៅក្នុងខែមករានេះដែរ ទន្លេសាបបានហូរនាំទឹក និងត្រីចេញពីបឹងទន្លេសាប ដែលជាជង្រុកត្រីយ៉ាងសំខាន់របស់ប្រទេសកម្ពុជា ហើយវាក៏ជាឱកាស និងប្រពៃណីរបស់ប្រជាពលរដ្ឋខ្មែរ ធ្វើប្រហុក ផ្អក ត្រីឆ្អើរ ត្រីងៀត សម្រាប់ការផ្គត់ផ្គង់ជីវភាពនៅឆ្នាំខាងមុខ។

ការប្រើប្រាស់គ្រឿងចក្រទាំងអស់ខាងលើ បានប្រឈមទៅនឹងគ្រោះថ្នាក់ ដោយសារមីនគ្រប់ប្រភេទ ជាពិសេសមីនតោនដែលបាត់ប្រវត្តិយ៉ាងច្រើនសន្ធឹកសន្ធាប់។ ដើម្បីទប់ស្កាត់នូវបញ្ហាប្រឈមទាំងអស់ខាងលើ នាយកដ្ឋានបានធ្វើការណែនាំ និងពង្រឹងស្មារតី ដល់បុគ្គលិកអប់រំមីនទាំងអស់ រួមមាននាយសម្របសម្រួលការងារមីនប្រចាំខេត្ត(PC) នាយតំណាងមីន/គ្រាប់ប្រចាំស្រុក (DFP) មន្ត្រីផ្នែកប្រតិបត្តិការតាមកងឯកភាពកំចាត់មីនទាំងអស់ ឲ្យយកចិត្តទុកដាក់ និងចុះទៅតាមគោលដៅសំខាន់ៗ ធ្វើការណែនាំប្រជាពលរដ្ឋឲ្យមានការប្រុងប្រយ័ត្នខ្ពស់ និងរាយការណ៍ជាបន្ទាន់នៅពេលណាបានជួបប្រទះគ្រាប់មីន/ស.ផ.ស ឬវត្ថុសង្ស័យ មកកាន់មន្ត្រីប៉ូលិស បណ្តាញមីន/គ្រាប់ស្ម័គ្រចិត្ត អាជ្ញាធរ មូលដ្ឋាន និងប្រតិបត្តិករបោសសំអាតមីនណាដែលនៅជិតបំផុត។

ខែមករានេះ នាយសម្របសម្រួលការងារមីន(PC)ប្រចាំខេត្ត និងនាយតំណាងមីន(DFP)ប្រចាំស្រុកទាំងអស់ នៅតែបន្តចុះធ្វើការសិក្សាជ្រើសរើសព្រះសង្ឃធ្វើជាបណ្តាញព្រះសង្ឃស្ម័គ្រចិត្ត ដើម្បីជួយបញ្ជ្រាប

ផ្សព្វផ្សាយការយល់ដឹងពីមីន/ស.ផ.ស នៅតាមភូមិ សាស្ត្រសំខាន់ៗមួយចំនួនដែលមានការគំរាមកំហែងខ្ពស់ ដើម្បីជួយជំរុញឲ្យការកាត់ បន្ថយអត្រាគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស កាន់តែមានប្រសិទ្ធភាព។

ទិន្នន័យអត្រាគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស ដែលរាយការណ៍ដោយ CMVIS គ្រោះថ្នាក់ដោយមីន និងស.ផ.ស មានចំនួន៣នាក់ ដូចមានរាយនាមខាងក្រោម៖

- ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ វេលាម៉ោង១,៣០នាទីរសៀល មានករណីផ្ទុះគ្រាប់( ស្លាប់១នាក់ ) ដោយសារជំគ្រាប់81m.m យករំសេវ កើតហេតុនៅភូមិបុស្សតាតុក ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ជនរងគ្រោះឈ្មោះ ទូន រិត ភេទប្រុស អាយុ៥៥ឆ្នាំ មុខរបរធ្វើស្រែ។
- ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ ដដែលវេលាម៉ោង១,០០នាទីរសៀល មានករណីផ្ទុះមីនស្ករដាច់ជើងស្តាំ(របួសធ្ងន់១នាក់)ដោយសារដើរដាក់អន្ទាក់សត្វ កើតហេតុនៅភូមិពាមតា ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង ជនរងគ្រោះឈ្មោះ សាយ ពៅ ភេទប្រុស អាយុ៥០ឆ្នាំ មានមុខរបរជាទាហាន។ **សូមបញ្ជាក់ថាៈ** ឈ្មោះនេះ កាលពីខែមករា ឆ្នាំ២០១៩កន្លងទៅ បានជាន់មីនស្ករដាច់ជើងឆ្វេង ម្តងរួចទៅហើយ។
- ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង១,០០នាទីរសៀល មានករណីផ្ទុះមីនស្ករដាច់ជើងស្តាំ (របួសធ្ងន់១នាក់)ដោយសារកាប់ចំការ ពនដី កើតហេតុនៅភូមិភ្នំរៃ ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង ជនរងគ្រោះឈ្មោះ សៅ អឿនពេជ្រ ភេទប្រុស អាយុ១៦ឆ្នាំ មានមុខរបរជាកសិករ។

បើប្រៀបធៀបទៅនឹងខែមករា ឆ្នាំ២០១ ៩ ដែលមានចំនួន១៨នាក់ ដោយសារមីនAP ចំនួន២នាក់ AT២នាក់ ERW ចំនួន១៤នាក់ ឃើញថាមានការថយចុះចំនួន **១៦.៦៦%**។

| កាលបរិច្ឆេទ | ស.ផ.ស | គ្រាប់មីន | | សរុប |
|---|---|---|---|---|
| | | AP | AT | |
| មករា-២០១៩ | 14 | 2 | 2 | **18** |
| មករា-២០២០ | 1 | 2 | 0 | **3** |

## ២-ស្ថានភាពបុគ្គលិកៈ

កម្មវិធីអប់រំការយល់ដឹងពីមីន និងស.ផ.ស នៅក្នុងខែមករានេះ មានបុគ្គលិកសរុបចំនួន **២៩**នាក់ ដោយបុគ្គលិកមួយចំនួនត្រូវបានបញ្ចប់កិច្ចសន្យា និងត្រៀមជ្រើសរើសបន្តសម្រាប់ខែក្រោយ។ បុគ្គលិកទាំងនោះកំពុងតែពង្រឹង/ពង្រីកសមត្ថភាព ដល់គណៈកម្មាធិការមីន/គ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្តមានមេភូមិ នាយប៉ុស្តិ៍នគរបាលទូទាំងប្រទេសចំនួន**៣,៤៥២**នាក់ ដែលកំពុងតែបំពេញប្រតិបត្តិការ នៅក្នុងតំបន់ទទួលរងនូវការគំរាមកំហែងពីមីន/ស.ផ.ស នានា ដែលមានសមាសាពដូចខាងក្រោម៖

## ក-បុគ្គលិកៈ

១-ប្រធាននាយកដ្ឋាន ០១ នាក់
២-អនុប្រធាននាយកដ្ឋាន ០១ នាក់
៣-ប្រធានការិ.អប់រំផ្សព្វផ្សាយមីន និងជួយជនពិការដោយសារមីន ០១ នាក់
៥-នាយសម្របសម្រួលការងារមីន/គ្រាប់ប្រចាំខេត្ត(ស្ត្រី២ បុរស៤) ០៦ នាក់
៦-នាយតំណាងមីនប្រចាំស្រុកCBMRR-DFP(ស្ត្រី៣ បុរស១២) ១៥នាក់
៧-នាយតំណាងគ្រាប់ប្រចាំស្រុក/ខេត្តCBURR-DFP(ស្ត្រី១ បុរស៤) ០៥នាក់

**សរុបរួមៈ ២៩នាក់**

## ១-បណ្តាញស្ម័គ្រចិត្តៈ

### ១-កម្មវិធីកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍(CBMRR)

ក-តំបន់គោលដៅរបស់កម្មវិធី CBMRR ចំនួន៤២៣ភូមិ ឃុំចំនួន១២៧ ស្រុកចំនួន៣៦ ខេត្តចំនួន៧ មានដូចជា ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានមានជ័យ ខេត្តសៀមរាប និងខេត្តព្រះវិហារ។

ខ-គណៈកម្មាធិការមីនស្ម័គ្រចិត្ត CBMRR បានចំនួន**១,២២០**នាក់។

### ២-កម្មវិធីកាត់បន្ថយគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍(CBURR & Police)

ក-តំបន់គោលដៅរបស់កម្មវិធី CBURR ចំនួន៤៩៤ភូមិ ឃុំចំនួន៣៣៧ ស្រុកចំនួន៩៦ ខេត្តចំនួន១៧ មានដូចជា ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្ត កំពង់ស្ពឺ ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តស្ទឹងត្រែង ខេត្តត្បូងឃ្មុំ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តតាកែវ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តប៉ៃលិន។

ខ-បង្កើតបណ្តាញគ្រាប់ស្ម័គ្រចិត្ត CBURR បានចំនួន**២,២៣២**នាក់ ក្នុងនោះមាន មន្ត្រីនគរបាលស្ម័គ្រចិត្ត៥៦៣នាក់ និងព្រះសង្ឃស្ម័គ្រចិត្ត២៩អង្គ ដែលបានបណ្តុះបណ្តាលរួច។

**សរុបរួមទាំង០២កម្មវិធី ចំនួន៣,៤៥២នាក់**

## ៣-ការពង្រាយកម្លាំង

### ក-កម្មវិធីកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍Community Based Mine Risk Reduction(CBMRR)

បច្ចុប្បន្ននេះមានបុគ្គលិកនាយតំណាងមីនប្រចាំស្រុក(DFP)ម្នាក់នៅតាមស្រុកគោលដៅទាំង១៧កំពុងដំណើរការរាល់ថ្ងៃចំនួន១៧នាក់ ពួកគេមានសមាសភាពជ្រើសចេញមកពីមន្ត្រីជំនាញជុំវិញសាលាស្រុក ជួយធ្វើការសម្របសម្រួលលើសេវាកម្មទាំងបីមានៈ សេវាកម្មមីន សេវាកម្មអភិវឌ្ឍន៍ និងសេវាកម្មជនពិការ។

## ១-កាដឯកភាពកំចាត់មីនដី១(បន្ទាយមានជ័យ)

1. នាយសម្របសម្រួលការងារមីនប្រចាំខេត្ត(PC)១នាក់ជាស្រ្តីទទួលខុសត្រូវលើការងារប្រចាំកងឯកភាព
2. បុគ្គលិកនាយតំណាងមីនប្រចាំស្រុក(DFP)ចំនួន៤នាក់ជាបុរស
   -ស្រុកម៉ាឡៃ ១នាក់
   -ស្រុកអូរជ្រៅ និងប៉ោយប៉ែត ១នាក់
   -ស្រុកស្វាយចេក ១នាក់
   -ស្រុកថ្មពួក ១នាក់
3. ព្រះសង្ឃស្ម័គ្រព្រះទ័យ ចំនួន ១៤អង្គ

## ២-កាដឯកភាពកំចាត់មីនដី២(បាត់ដំបង)

1. នាយសម្របសម្រួលការងារមីនប្រចាំខេត្ត(PC) ១នាក់ជាស្រ្តី ទទួលខុសត្រូវលើការងារប្រចាំកងឯកភាព
2. បុគ្គលិកនាយតំណាងមីនប្រចាំស្រុក(DFP) ចំនួន៧នាក់ ក្នុងនោះស្រ្តី ២នាក់
   -ស្រុកបវេល ខេត្តបាត់ដំបង ១នាក់
   -ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ១នាក់ (ស្រ្តី)
   -ស្រុកបាណន់ ខេត្តបាត់ដំបង ១នាក់(ស្រ្តី)
   -ស្រុកគាស់ក្រឡខេត្តបាត់ដំបង ១នាក់
   -ស្រុកមោងឬស្សី/រុក្ខគីរី ខេត្តបាត់ដំបង ១នាក់
   -ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ១នាក់
   -ស្រុកវាលវែង ខេត្តពោធិ៍សាត់ ១នាក់
3. មន្ត្រីនគរបាលស្ម័គ្រចិត្តថ្នាក់ខេត្ត ០២នាក់ ជាបុរស(សមាសភាពជាមន្ត្រីថ្នាក់ការិយាល័យគ្រប់គ្រងកិច្ចការប៉ុស្តិ៍) នៃស្នងការដ្ឋាននគរបាលខេត្តៈ
   -ខេត្តបាត់ដំបង ០១នាក់
   -ខេត្តពោធិ៍សាត់ ០១នាក់
   -ខេត្តកំពង់ឆ្នាំង ០១នាក់
4. ព្រះសង្ឃស្ម័គ្រព្រះទ័យ ចំនួន ០៧អង្គ

## ៣-កាដឯកភាពកំចាត់មីនដី៣(ប៉ៃលិន)

1. នាយសម្របសម្រួលការងារមីនប្រចាំខេត្ត(PC)១នាក់ជាបុរស ទទួលខុសត្រូវលើ ការងារប្រចាំកងឯកភាព
2. បុគ្គលិកនាយតំណាងមីនប្រចាំស្រុក(DFP)ចំនួន៦នាក់ ក្នុងនោះស្រ្តី១(ចូលនិវត្តន៍០២នាក់)
   -ស្រុកសំពៅលូន ខេត្តបាត់ដំបង ១នាក់

-ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ១នាក់
-ស្រុកកំរៀង ខេត្តបាត់ដំបង ១នាក់ (បញ្ចប់កិច្ចសន្យា)
-ស្រុកសំឡូត ខេត្តបាត់ដំបង ១នាក់ (ស្ត្រី)
-ក្រុងប៉ៃលិន ខេត្តប៉ៃលិន ១នាក់
-ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ១នាក់ (បញ្ចប់កិច្ចសន្យា)

3. មន្ត្រីនគរបាលស្ម័គ្រចិត្តថ្នាក់ខេត្ត ០១នាក់ ជាបុរស (សមាសភាពជាមន្ត្រីថ្នាក់ការិយាល័យគ្រប់គ្រង កិច្ចការប៉ុស្តិ៍) នៃស្នងការដ្ឋាននគរបាលខេត្ត៖
4. ព្រះសង្ឃស្ម័គ្រព្រះទ័យ ចំនួន ០២អង្គ

## ខ-កម្មវិធីកាត់បន្ថយគ្រោះថ្នាក់គ្រាប់តាមសហគមន៍ Community Based UXO Risk Reduction(CBURR)

កម្មវិធីនេះយើងពង្រីកបាន៤៩៤ភូមិ ៣៣៧ឃុំ ៦១ស្រុក ស្ថិតក្នុង១៣ខេត្តគោលដៅ ប៉ុន្តែបច្ចុប្បន្ននេះ យើងបានកែលម្អសមាសសភាពអ្នកស្ម័គ្រចិត្ត ភាគច្រើនជាមន្ត្រីនាយប៉ុស្តិ៍នគរបាលឃុំ/សង្កាត់ រួមទាំងព្រះសង្ឃស្ម័គ្រព្រះទ័យមួយចំនួនផងដែរ ដើម្បីជួយផ្សព្វផ្សាយព័ត៌មានសុវត្ថិភាពគ្រាប់មីន/ស.ផ.ស តាមផ្លូវព្រះធម៌ទៅដល់ពុទ្ធបរិស័ទ និងស្របតាមការអនុវត្តគោលនយោបាយ (ភូមិ-ឃុំមានសុវត្ថិភាព) របស់រាជរដ្ឋាភិបាល ដោយរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងដូចជា មាននាយ សម្របសម្រួលការងារគ្រាប់ប្រចាំខេត្ត(PC) នៅតាមកងឯកភាព ដូចខាងក្រោម៖

### ១-កងឯកភាពកំចាត់មីនទី៤(សៀមរាប និងកំពង់ធំ)

1) នាយសម្របសម្រួលការងារគ្រាប់ប្រចាំខេត្ត(PC)១នាក់ ជាបុរស ទទួលខុសត្រូវលើការងារប្រចាំកងឯកភាព
2) បុគ្គលិកនាយតំណាងគ្រាប់ប្រចាំស្រុក(DFP)ចំនួន២នាក់ ក្នុងនោះយុវនារី១នាក់
   -ស្រុកជីក្រែង ១នាក់ (បុរស)
   -ស្រុកកំពង់ស្វាយ ១នាក់ (យុវនារី សមាសសភាពមន្ត្រីនគរបាលស្រុក)
3) មន្ត្រីនគរបាលស្ម័គ្រចិត្តថ្នាក់ខេត្ត២នាក់ សមាសភាពថ្នាក់ការិយាល័យគ្រប់គ្រងកិច្ចការប៉ុស្តិ៍នៃស្នងការដ្ឋាននគរបាលខេត្ត៖
   -ខេត្តសៀមរាប ១នាក់
   - ខេត្តកំពង់ធំ ១នាក់
4) ព្រះសង្ឃស្ម័គ្រព្រះទ័យ ចំនួន ០៦អង្គ

### ២-កងឯកភាពកំចាត់មីនទី៥(ខេត្តត្បូងឃ្មុំ)

1) បុគ្គលិកនាយសម្របសម្រួលការងារគ្រាប់ប្រចាំខេត្ត(PC)១នាក់ ជាបុរស ប្រចាំកងឯកភាព
2) បុគ្គលិកនាយតំណាងគ្រាប់ប្រចាំស្រុក/ខេត្ត(DFP)ចំនួន៣នាក់ជាបុរស

-ខេត្តស្ទឹងត្រែង ១នាក់ (សមាសភាពមន្ត្រីនគរបាលថ្នាក់ការិយាល័យគ្រប់គ្រងកិច្ចការប៉ុស្តិ៍)
-ខេត្តស្វាយរៀង១នាក់(សមាសភាពមន្ត្រីនគរបាលថ្នាក់ការិយាល័យគ្រប់គ្រងកិច្ចការប៉ុស្តិ៍)
-ខេត្តព្រៃវែង១នាក់ (សមាសភាពមន្ត្រីនគរបាលថ្នាក់ការិយាល័យគ្រប់គ្រងកិច្ចការប៉ុស្តិ៍)

## ៣-កាដឯកកភាពកំចាត់មីនជី៦(ព្រះវិហារ)

1) បុគ្គលិកនាយសម្របសម្រួលការងារគ្រាប់ប្រចាំខេត្ត(PC)១នាក់ជាបុរស ប្រចាំកងឯកភាព
2) បុគ្គលិកនាយតំណាងគ្រាប់ប្រចាំស្រុក(DFP)ចំនួន៣នាក់ ជាបុរស (បានបញ្ចប់កិច្ចសន្យា)
-ស្រុកឆែប ១នាក់ បញ្ចប់កិច្ចសន្យា ត្រៀមជ្រើសរើស
-ស្រុកជាំក្សាន្ត ១នាក់ បញ្ចប់កិច្ចសន្យា
-ស្រុកអន្លង់វែង ១នាក់ បញ្ចប់កិច្ចសន្យា ត្រៀមជ្រើសរើស
3) មន្ត្រីនគរបាលស្ម័គ្រចិត្តថ្នាក់ខេត្ត២នាក់ ជាបុរស (សមាសភាពជានាយការិយាល័យគ្រប់គ្រងកិច្ចការប៉ុស្តិ៍) នៃស្នងការដ្ឋាននគរបាលខេត្តៈ
-ខេត្តឧត្តរមានមានជ័យ ១នាក់
- ខេត្តព្រះវិហារ ១នាក់

### ត-ក្រុមអប់រំផ្សេងៗរបស់ស៊ីម៉ាក់:

ក្រៅពីក្រុមអប់រំខាងលើ ការអប់រំយល់ដឹងពីមីន/ស.ផ.ស ក៏បានអនុវត្តនៅតាមក្រុមប្រតិបត្តិការផ្សេងៗ ដូចជាក្រុម EOD, BAC, BAC-L, BAC-MTT, BAC-S, BC, DM, ERWI, LLD, BLS, CRWS, DIV, ECS, EDO, EDD, MDR, NTS, OPS-DU, SLD, TSC and Mobile Platoon ដែលបាននឹងកំពុងបំពេញប្រតិបត្តិការនៅតាមកងឯកភាពកំចាត់មីននានា និងក្រុមស្ថិតនៅក្រោមចំណុះទីបញ្ជាការភ្នំពេញ។

## ៤-សកម្មភាពនិងលទ្ធផលការងារអប់រំផ្សព្វផ្សាយយល់ដឹងពីមីន/ERW របស់ក្រុមនីមួយៗ

### ៤.១-សកម្មភាពកាត់បន្ថយគ្រោះថ្នាក់មីន/គ្រាប់តាមសហគមន៍CBMRR-CBURR

ក្រុមការងារអប់រំមីនទាំងកម្មវិធីCBMRR,CBURR ក្រុមចល័តរបស់ស៊ីម៉ាក់ ព្រះសង្ឃ និងមន្ត្រីនគរបាលជាតិដែលបានដូចរៀបរាប់ខាងលើ បានចុះធ្វើការអប់រំការយល់ដឹងពីមីន/ស.ផ.ស នៅតាមគោលដៅសំខាន់ៗដែលប្រឈមនឹងការគ្រោះថ្នាក់មីន/ស.ផ.សដូចជាៈ សកម្មភាពជាំដុះ និងការប្រមូលផលរបស់ប្រជាកសិករ សកម្មភាពរុករកអនុផលព្រៃឈើ សកម្មភាពរុករានដីថ្មី ការប្រើប្រាស់គ្រឿង ចក្រផុនធូន់នៅ ក្នុងតំបន់ដែលប្រឈមនឹងមីនតោន។

ការកែច្នៃគ្រាប់បោកគ្រី សកម្មភាពរុករកដែកលក់ឲ្យអេតចាយ និង ការបញ្ជ្រាបការយល់ដឹងពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម នៅតាមសាលារៀន វត្តអារ៉ាមមួយចំនួនផងដែរ។ ជាពិសេសផ្តោតទៅលើកុមារតូចៗដែលតែងតែរពិស និងមិនទាន់ស្គាល់អ្វីដែលជាគ្រឿងផ្ទុះ។ ក្រុមការងារអប់រំមីនក៏បានធ្វើការចែ ករំលែកនូវ

ចំណេះដឹងអំពី ការយល់ដឹងពីមីនមួយចំនួនដល់ប្រជាពលរដ្ឋ សហគមន៍ សាលារៀន និង ព្រះសង្ឃតាមវត្តអារ៉ាមមួយចំនួន ដើម្បីឲ្យពួកគេអាចយកទៅធ្វើការអប់រំបន្ត ធ្វើយ៉ាងណាជួយទប់ស្កាត់ការគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស ដែលជាការរួមចំណែកក្នុងការអនុវត្តន៍គោលនយោបាយ(ភូមិ-ឃុំមានសុវត្ថិភាព)របស់រាជរដ្ឋាភិបាល។

ជាមួយគ្នានេះផងដែរ ក្រុមចល័តស៊ីម៉ាក់ ក៏បានធ្វើការឆ្លើយតបក្នុងការដោះយកគ្រាប់មិនទាន់ផ្ទុះ និងគ្រាប់មីនដែលប្រជាពលរដ្ឋបានរាយការណ៍បានទាន់ពេលវេលាផងដែរ ដើម្បីធ្វើឲ្យប្រជាពលរដ្ឋមានជំនឿទុកចិត្តមកលើស្ថាប័នស៊ីម៉ាក់ ដែលជាស្ថាប័នជាតិ ក្នុងការផ្តល់សេចក្តីសុខ និងសុវត្ថិភាពទៅដល់ពួកគេ។

នៅក្នុងខែមករា ជារដូវកាលបញ្ចប់នៃការប្រមូលផលស្រូវស្រែ ចំណែកឯការងារចំការប្រជាពលរដ្ឋបាននឹងកំពុងប្រើប្រាស់គ្រឿងចក្រធុនធ្ងន់ ដឹកជញ្ជូនពោត/ដំឡូងនៅក្នុងដីចំការ ដែលជាតំបន់មីនតោនបាត់ប្រវត្តិគឺជាការប្រឈមនឹងគ្រោះថ្នាក់ខ្ពស់។ នាយកដ្ឋានបានធ្វើការណែនាំដល់គ្រប់ក្រុមការងារអប់រំផ្សព្វផ្សាយមីនចុះយុទ្ធនាការធ្វើការអប់រំការយល់ដឹងពីមីន/ស.ផ.សនៅតាមគោលដៅសំខាន់ៗមួយចំនួនដូចជាការប្រើត្រាក់ទ័រគោយន្ត និងរថយន្តដឹកកសិផលជាដើម។

## ៤.២-លទ្ធផលការអប់រំរបស់កម្មវិធី CBMRR

កម្មវិធីកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍(CBMRR) បាននឹងកំពុងអនុវត្តការងារអប់រំមីន/គ្រាប់ដើម្បីកាត់បន្ថយគ្រោះថ្នាក់តាមសហគមន៍ ដែលកំពុងទទួលរងនូវការគំរាមកំហែងពីគ្រាប់មីន/ស.ផ.ស ទៅលើខេត្តចំនួន៥ មានដូចជា ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ដែលមានស្រុកចំនួន**១៦** ឃុំចំនួន**៦៧** ភូមិចំនួន**១៨៣** ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

| DU | ក្រុម ប្រតិបត្តិការ | តំបន់ប្រតិបត្តិការ | | | | លទ្ធផលអប់រំទទួលបាន | | | | | | | សម្ភារៈចំណាយ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនវគ្គអប់រំ | ប្រុស | ស្រី | ក្នុងសាលា | ក្រៅសាលា | សរុប | ចំនួនខ្នងផ្ទះ | អាវយឺត | សៀវភៅសរសេរ | ផ្ទាំងរូបភាព | ខិត្តប័ណ្ណ |
| DU01 | ស្វាយចេក | BMC | 1 | 4 | 16 | 16 | 147 | 128 | 308 | 40 | 623 | 63 | | | | |
| | ថ្មពួក | BMC | 1 | 2 | 13 | 15 | 295 | 249 | 33 | 40 | 617 | 77 | | | | |
| | ម៉ាឡៃ | BMC | 1 | 4 | 13 | 14 | 278 | 260 | 88 | 13 | 639 | 122 | | | | |
| | ប៉ោយប៉ែត | BMC | 1 | 7 | 12 | 16 | 232 | 265 | 133 | 57 | 687 | 134 | | | | 38 |
| | PC | BMC | | | | | | | | | | | | | | |
| សរុប | | 1 | 4 | 17 | 54 | 61 | 952 | 902 | 562 | 150 | 2,566 | 396 | | | | 38 |
| DU2 | បវេល | BTB | 1 | 4 | 15 | 48 | 322 | 383 | 77 | 96 | 878 | 290 | | | | |
| | រតនៈមណ្ឌល | BTB | 1 | 3 | 11 | 22 | 175 | 193 | 93 | 107 | 568 | 411 | | | | |
| | គាស់ក្រឡ | BTB | 1 | 3 | 8 | 17 | 249 | 171 | 238 | | 658 | 220 | | | | |
| | ភ្នំក្រវ៉ាញ | BTB | 1 | 4 | 11 | 19 | 145 | 151 | 312 | 80 | 688 | 114 | | | | |
| | វាលវែង | BTB | 1 | 5 | 14 | 34 | 181 | 225 | 82 | 70 | 558 | 371 | | | | |
| | បាណន់ | BTB | 1 | 4 | 13 | 20 | 219 | 176 | 155 | 200 | 750 | 95 | | | | |

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | រុក្ខគីរី | BTB | 1 | 6 | 9 | 32 | 243 | 240 | 115 | 114 | 712 | 233 | | | | |
| | PC | BTB | | | | | | | | | | | | | | |
| **សរុប** | | **3** | **7** | **29** | **81** | 192 | 1,534 | 1,539 | 1,072 | 667 | 4,812 | 1,734 | | | | |
| DU3 | សំពៅលូន | BTB | 1 | 6 | 15 | 39 | 240 | 240 | 125 | 75 | 680 | 138 | | | | |
| | ភ្នំព្រឹក | BTB | 1 | 4 | 7 | 16 | 307 | 224 | 64 | 52 | 647 | 128 | | | | |
| | កំរៀង | BTB | | | | | | | | | | | | | | |
| | សំឡូត | BTB | 1 | 7 | 16 | 70 | 337 | 272 | 197 | 170 | 976 | 354 | | | | |
| | ប៉ៃលិន | PLN | 1 | 3 | 8 | 46 | 297 | 275 | 91 | 45 | 708 | | | | | |
| | សាលាក្រៅ | PLN | | | | | | | | | | | | | | |
| | PC | PLN | 1 | 1 | 2 | 3 | 6 | 6 | 52 | | 64 | 59 | | | | |
| **សរុប** | | **1** | **5** | **21** | **48** | 174 | 1,187 | 1,017 | 529 | 342 | 3,075 | 679 | | | | |
| Grand Total | | 5 | 16 | 67 | 183 | 427 | 3,673 | 3,458 | 2,163 | 1,159 | 10,453 | 2,809 | - | - | - | 38 |

## ៤.៣-លទ្ធផលការអប់រំកម្មវិធី CBURR

កម្មវិធីកាត់បន្ថយគ្រោះថ្នាក់គ្រាប់តាមសហគមន៍(CBURR) បាននឹងកំពុងអនុវត្តការងារអប់រំមីន/គ្រាប់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់តាមសហគមន៍ ដែលកំពុងទទួលរងនូវការគំរាមកំហែងពីគ្រាប់មីន/ស.ផ.ស ទៅលើខេត្តចំនួន៧ មានដូចជា ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តព្រៃវែង និងខេត្តស្វាយរៀង នៅក្នុងស្រុកចំនួន១៥ ឃុំចំនួន៣៧ និងភូមិចំនួន៦៣ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

| DU | ក្រុម ប្រតិបត្តិការ | តំបន់ប្រតិបត្តិការ | | | | លទ្ធផលអប់រំទទួលបាន | | | | | | | សម្ភារៈចំណាយ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនវគ្គអប់រំ | ប្រុស | ស្រី | ក្នុងសាលា | ក្រៅសាលា | សរុប | ចំនួនផ្ទះ | អាវយឺត | សៀវភៅសរសេរ | ផ្ទាំងប្រកាស | ខិត្តប័ណ្ណ |
| DU4 | កំពង់ស្វាយ | KTM | 1 | 8 | 14 | 15 | 83 | 116 | 223 | 119 | 541 | 270 | | | 200 | 53 |
| | ជីក្រែង | SRP | 1 | 9 | 18 | 18 | 90 | 111 | 272 | 9 | 482 | 308 | | | | 18 |
| | PC | SRP | | | | | | | | | | | | | | |
| **សរុប** | | **2** | **2** | **17** | **32** | **33** | **173** | **227** | **495** | **128** | **1,023** | **578** | | | **200** | **71** |
| DU5 | ស្ទឹងត្រែង | STR | 2 | 2 | 6 | 6 | 255 | 358 | 126 | 160 | 899 | | | | | |
| | ស្វាយរៀង | SVR | 4 | 9 | 14 | 14 | 3,749 | 2,820 | 921 | 98 | 7,588 | | | | | |
| | ព្រៃវែង | PRV | 7 | 9 | 11 | 11 | 744 | 849 | 2,389 | 36 | 4,018 | 1,407 | | | | |
| | PC | TBK | | | | | | | | | | | | | | |
| **សរុប** | | **3** | **13** | **20** | **31** | **31** | **4,748** | **4,027** | **3,436** | **294** | **12,505** | **1,407** | | | | |
| DU6 | ឆែប | PVH | | | | | | | | | | | | | | |
| | ជាំក្សាន្ត | OMC | | | | | | | | | | | | | | |
| | អន្លង់វែង | OMC | | | | | | | | | | | | | | |
| | PC | PVH | | | | | | | | | | | | | | |
| **សរុប** | | **2** | | | | | | | | | | | | | | |
| Grand Total | | 7 | 15 | 37 | 63 | 64 | 4,921 | 4,254 | 3,931 | 422 | 13,528 | 1,985 | - | - | 200 | 71 |

## ៤.៤-លទ្ធផលការអប់រំក្រុមចល័តស៊ីម៉ាក់

កង/ក្រុមចល័តនៃកងឯកភាពកំចាត់មីនទាំង៦ ដែលមានចំនួន ៣កងបោសសំអាតមីន និង៧៦ក្រុមចល័ត បាននិងកំពុងអនុវត្តការងារអប់រំមីន/ស.ផ.ស នៅតាមសហគមន៍ដែលទទួលរងនូវការគំរាមកំហែងពីគ្រាប់មីន/ស.ផ.ស។ ក្នុងខែមករានេះ នៅកងឯកភាពកំចាត់មីនទី៥ មានការដាក់ពង្រាយក្រុមស្រាវជ្រាវមូលដ្ឋាន (Baseline Survey)ចំនួន១១ក្រុមផងដែរ។ ការអប់រំមីន បានអនុវត្តនៅលើភូមិ ចំនួន២៣២ ក្នុងឃុំចំនួន១២១ ស្រុកចំនួន៦៤ និងខេត្តចំនួន១៩ ហើយទទួលបានលទ្ធផលដូចខាងក្រោម៖

| DU | ចំនួនក្រុម | តំបន់ប្រតិបត្តិការ | | | | លទ្ធផលអប់រំបាន | | | | | | | សម្ភារៈចំណាយ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនខេត្ត | ចំនួនស្រុក | ចំនួនឃុំ | ចំនួនភូមិ | ចំនួនវគ្គអប់រំ | ប្រុស | ស្រី | កុមារក្នុងសាលា | កុមារក្រៅសាលា | សរុប | ចំនួនខ្នងផ្ទះ | អាវយឺត | សៀវភៅសរសេរ | ផ្ទាំងរូបភាព | ខិត្តប័ណ្ណ |
| DU1 | 7 | 1 | 6 | 9 | 15 | 7 | 41 | 19 | 22 | 187 | 269 | | | 200 | 7 | 10 |
| DU2 | 19 | 3 | 10 | 18 | 19 | 30 | 138 | 114 | 21 | 63 | 336 | 7 | | | 2 | 6 |
| DU3 | 7 | 1 | 2 | 5 | 12 | 21 | 203 | 95 | | 12 | 310 | 46 | | | | |
| DU4 | 9 | 1 | 11 | 25 | 28 | 72 | 296 | 253 | | 147 | 696 | 331 | | | 72 | |
| DU5 | 23 | 7 | 37 | 58 | 160 | 313 | 2,165 | 1,718 | 328 | 1,314 | 5,525 | 2,505 | | | | |
| DU6 | 12 | 2 | 5 | 10 | 13 | 29 | 148 | 141 | | 150 | 439 | | | | | |
| TIMA | 2 | 4 | 11 | 28 | 31 | 3 | 20 | 25 | 53 | 13 | 111 | | | | | |
| **Grand Total:** | **79** | **19** | **64** | **121** | **232** | **475** | **3,011** | **2,365** | **424** | **1,886** | **7,686** | **2,889** | | **200** | **81** | **16** |

## ៤.៥-លទ្ធផលការអប់រំផ្សព្វផ្សាយរបស់មន្ត្រីនគរបាលស្ម័គ្រចិត្ត

មន្ត្រីនគរបាលជាតិស្ម័គ្រចិត្ត បាននិងកំពុងអនុវត្តការងារអប់រំមីន/ស.ផ.ស ដើម្បីកាត់បន្ថយគ្រោះថ្នាក់តាមសហគមន៍ ដែលទទួលរងនូវការគំរាមកំហែងពីគ្រាប់មីន/ស.ផ.ស ទៅលើខេត្តចំនួន៨មាន: ឧត្តរមានជ័យ, សៀមរាប កំពង់ធំ ព្រះវិហារ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងប៉ៃលិន នៅក្នុងស្រុកចំនួន១៥ ក្នុងឃុំចំនួន៥១ និងភូមិចំនួន២៧១ ហើយទទួលបានលទ្ធផល ដូចខាងក្រោម៖

| DU | ក្រុមប្រតិបត្តិការ | តំបន់ប្រតិបត្តិការ | | | | លទ្ធផលអប់រំទទួលបាន | | | | | | | សម្ភារៈចំណាយ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនវគ្គអប់រំ | ប្រុស | ស្រី | ក្នុងសាលា | ក្រៅសាលា | សរុប | ចំនួនខ្នងផ្ទះ | អាវយឺត | សៀវភៅសរសេរ | ផ្ទាំងរូបភាព | ខិត្តប័ណ្ណ |
| DU2 | Police | BTB | 4 | 8 | 11 | 10 | 1,932 | 2,030 | 1,297 | 747 | 6,006 | 16,611 | | | | |
| | Police | KPC | 3 | 13 | 180 | 588 | 39,759 | 45,250 | 5,868 | 2,422 | 93,299 | | | | | |
| | Police | PST | 3 | 11 | 31 | 42 | 2,589 | 1,392 | 567 | 275 | 4,823 | | | | | |
| **Total** | | **3** | **10** | **32** | **222** | **640** | **44,280** | **48,672** | **7,732** | **3,444** | **104,128** | **16,611** | | | | |
| DU3 | Police | PLN | 2 | 8 | 9 | 9 | 724 | 822 | 186 | 69 | 1,801 | 763 | | | | |
| **Total** | | **1** | **2** | **8** | **9** | **9** | **724** | **822** | **186** | **69** | **1,801** | **763** | | | | |
| DU4 | Police | KTM | 1 | 4 | 11 | 18 | 1,797 | 3,796 | 1,370 | 81 | 7,044 | 3,659 | | | | 18 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Police | SRP | 1 | 4 | 13 | 18 | 1,058 | 1,622 | 221 | 116 | 3,017 | 1,505 | | | 18 | |
| **Total** | | **2** | **2** | **8** | **24** | **36** | **2,855** | **5,418** | **1,591** | **197** | **10,061** | **5,164** | | | **18** | **18** |
| DU6 | Police | OMC | 1 | 3 | 17 | 18 | 1,419 | 1,181 | 1,690 | 1,037 | 5,327 | | | | | |
| | Police | PVH | | | | | | | | | | | | | | |
| **Total** | | **2** | **1** | **3** | **17** | **18** | **1,419** | **1,181** | **1,690** | **1,037** | **5,327** | | | | | |
| **Grand Total** | | **8** | **15** | **51** | **272** | **703** | **49,278** | **56,093** | **11,199** | **4,747** | **121,317** | **22,538** | **-** | **-** | **18** | **18** |

## ៤.៦-លទ្ធផលសរុបរួមប្រចាំខែមករា ការអប់រំផ្សព្វផ្សាយយល់ដឹងពីមីន/ERW

| DU | ទីកន្លែងចុះអប់រំ | | | | លទ្ធផលអប់រំទទួលបាន | | | | | | | សម្ភារៈចំណាយ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនខេត្ត | ចំនួនស្រុក | ចំនួនឃុំ | ចំនួនភូមិ | ចំនួនវគ្គអប់រំ | ប្រុស | ស្រី | ក្មេងក្នុងសាលា | ក្មេងក្រៅសាលា | សរុប | ចំនួនខ្នងផ្ទះ | អាវយឺត | សៀវភៅសរសេរ | ផ្ទាំងរូបភាព | ខិត្តប័ណ្ណ |
| CBMRR | 5 | 16 | 67 | 183 | 427 | 3,673 | 3,458 | 2,163 | 1,159 | 10,453 | 2,809 | | | | 38 |
| CBURR | 7 | 15 | 37 | 63 | 64 | 4,921 | 4,254 | 3,931 | 422 | 13,528 | 1,985 | | | 200 | 71 |
| Team | 19 | 64 | 121 | 232 | 475 | 3,011 | 2,365 | 424 | 1,886 | 7,686 | 2,889 | | 200 | 81 | 16 |
| Police | 8 | 15 | 51 | 272 | 703 | 49,278 | 56,093 | 11,199 | 4,747 | 121,317 | 22,538 | | | 18 | 18 |
| **Grand Total:** | **39** | **110** | **276** | **750** | **1,669** | **60,883** | **66,170** | **17,717** | **8,214** | **152,984** | **30,221** | **-** | **200** | **299** | **143** |

# ៥.លទ្ធផលនៃកិច្ចសហការណ៍:

## ៥.១-សំណើសុំ និងការឆ្លើយតបរបស់ក្រុមកម្ទេចគ្រឿងផ្ទុះ

| ក្រុមចុះអប់រំ | | សំណើសុំពីសហគមន៍ | | | | | ការឆ្លើយតប | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនសំណើ | AP | AT | UXO | គ្រាប់តូចៗ.Kg | ចំនួនសំណើ | AP | AT | UXO | គ្រាប់តូចៗ.Kg |
| CBMRR | DU1 | **8** | **4** | | **11** | | **8** | **4** | | **11** | |
| | DU2 | **8** | **2** | | **19** | | **5** | **1** | | **17** | |
| | DU3 | **10** | **8** | **1** | **29** | | **10** | **8** | **1** | **29** | |
| **Total** | **3** | **26** | **14** | **1** | **59** | | **23** | **13** | **1** | **57** | |
| CBURR | DU4 | 6 | | | 7 | | | | | | |
| | DU5 | 24 | | | 68 | | 24 | | | 68 | |
| | DU6 | | | | | | | | | | |
| **Total** | **2** | **30** | | | **75** | | **24** | | | **68** | |
| Police | បាត់ដំបង BTB | 5 | 5 | 2 | 14 | | 5 | 5 | 2 | 15 | |
| | កំពង់ឆ្នាំង KCH | 2 | 6 | 1 | 5 | 10 | 2 | 2 | 1 | 3 | 7 |
| | ប៉ៃលិន PLN | 1 | 3 | | 2 | | 1 | 3 | | 2 | |
| | ពោធិ៍សាត់ PST | 5 | | | 22 | | | | | 22 | |
| | ឧត្តរមានជ័យ OMC | 2 | | | 2 | 68 | 2 | | | 2 | 68 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | សៀមរាប SRP | | | | | | | | | | |
| | កំពង់ធំ KPTH | | | | | | | | | | |
| | ព្រះវិហារ PVH | | | | | | | | | | |
| **Total** | **8** | **15** | **14** | **3** | **45** | **78** | **10** | **10** | **3** | **44** | **75** |
| CMAC Team | DU1 | 12 | 210 | 1 | 42 | | 12 | 210 | 1 | 42 | |
| | DU2 | 7 | 3 | | 43 | | 7 | 3 | | 43 | |
| | DU3 | | | | | | | | | | |
| | DU4 | 29 | 1 | | 82 | 13 | 29 | 1 | | 82 | 13 |
| | DU5 | 153 | | 4 | 737 | 78 | 153 | | 5 | 736 | 77 |
| | DU6 | | | | | | | | | | |
| | TIMA | | | | | | | | | | |
| **Total** | **5** | **201** | **214** | **5** | **904** | **91** | **201** | **214** | **6** | **903** | **90** |
| **Grand Total:** | | **272** | **242** | **9** | **1,083** | **169** | **258** | **237** | **10** | **1,072** | **165** |

# ផែនទីពង្រាយកម្លាំង អប់រំផ្សព្វផ្សាយការយល់ដឹងពីមីន/ស.ផ.ស
# ប្រចាំខែមករា ឆ្នាំ២០២០

**Demining Unit 1**
- 1 PC
- 1 DFP Thmar Puok
- 1 DFP SvayChek
- 1DFP Ou Chrov/Poi Paet
- 1 DFP Malai
- 1 BAC 14
- 1 BC 09
- 1 ERWI 16
- 1 MPL 109
- 1 TSC 15
- 1 TSC 19
- 1 TSC 07
- 1 TSC 11
- 1 TSC 13
- 1 TSC 19
- 1 TSC 24
- 1 TSC 28

**Demining Unit 6**
- 1 PC
- 1 DFP ChoamKhsan
- 1 DFP Chhaeb
- 1 DFP AnlungVaeng
- 1 Police PVH
- 1 Police OMC
- 1 TSC 20
- 1 TSC 05
- 1 EOD 08




**Demining Unit 4**
- 1 PC
- 1 DFP Chikraeng
- 1 DFP Kampong Svay
- 1 Police Siem Reap
- 1 Police Kg. Thom
- 1 BC 06
- 1 BC 25
- 1 CM 01
- 1 DM 04
- 1 EOD 22
- 1 EOD Sup.
- 1 ERWI 01
- 1 MDR 01
- 1 TSC 16
- 1 TSC 22

**Demining Unit 3**
- 1 PC
- 1 DFP SampovLoun
- 1 DFP Phnom Proek
- 1 DFP Kamrieng
- 1 DFP Salakrao
- 1 DFP Pailin
- 1 DFP Samlout
- 1 ASST OPS
- 1 BAC 19
- 1 BC 10
- 1 MPL 147
- 1 TSC 02
- 1 TSC 06
- 1 TSC 10
- 1 TSC 14
- 1 TSC 18
- 1 TSC 25
- 1 TSC 30

**Demining Unit 2**

-1 PC
-1 DFP Banan
-1 DFP Bavel
-1 DFP Ratanak Mondul
-1 DFP Kaes Kralor
-1 DFP Moung/Rukhakiri
-1 DFP Phnom Kravanh
-1 DFP Veal Vaeng
-1 BC 12
-1 DM 08
-1 ERWI 18
-1 ERWI 13
-1 NTS 03
-1 NTS 02
-1 MPL 119
-1 MPL 135
-1 MPL 148
-1 SLD 02
-1 TSC 27
-1 TSC 04
-1 TSC 09
-1 TSC 12
-1 TSC 17

**Demining Unit 5**

1- PC
1- DFP Stung Traeng
1- DFP Prey Vaeng
1- DFP Svay Rieng
1- BAC-L 01
1- BAC-L 02
1- BAC-MTT 10
1- BAC-MTT 14
1- BAC-MTT 23
1- BAC-S 07
1- BAC-S 11
1- BAC-S 04
1- BAC-S 05
1- BAC-S 08
1- BAC-S 10
1- BAC-S 12
1- BAC-S 13
1- BAC-S 15
11- BLS
1- EDD 02
1-EDD05
1-OPS DU
1-QA-BLS

នៅក្នុងខែមករានេះ ការងារអប់រំមីន និងគ្រាប់មិនទាន់ផ្ទុះ បានអនុវត្តនៅលើតំបន់ដែលមានការប៉ះពាល់ដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ក្នុងស្រុកចំនួន១១០ ក្នុងឃុំចំនួន២៧៦ ក្នុងភូមិចំនួន៧៥០ ដូចមានការបង្ហាញនៅលើផែនទីនេះ។

## ៦-គម្រោងអភិវឌ្ឍន៍សហគមន៍ក្រោយការបោសសំអាតមីនរួច:

### ក-សកម្មភាពការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍកសិកម្ម:

ចាប់ពីថ្ងៃទី ០១ខែមករា ឆ្នាំ២០២០ ដល់ ថ្ងៃទី ៣១ ខែមករាឆ្នាំ២០២០ ការិយាល័យស្រាវជ្រាវកសិកម្ម បានអនុវត្តការងារដូចខាងក្រោម៖

**១- ការអនុវត្តការងារ:**

1) ការងាររៀបចំបង្កើតសហគមន៍កសិកម្ម និងការបណ្តុះបណ្តាលកសិកម្ម

2) ការងារអនុវត្តគម្រោង Sorgum Cultivation JICA Project, 2019។

**២- លទ្ធផលការងារ:**

1) **ការងាររៀបចំសហគមន៍កសិកម្ម**

- បានសហការណ៍ជាមួយ ការិយាល័យអភិវឌ្ឍសហគមន៍កសិកម្ម នៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបងស្តីពី ការរៀបចំសហគមន៍កសិកម្ម នៅមណ្ឌលអភិវឌ្ឍសហគមន៍ស៊ីម៉ាក់មរតកតេជោ ដើម្បីជ្រើសរើសសមាជិកសហគមន៍បន្ថែម ដោយសម្រេចបានសមាជិកចំនួន៣២នាក់ក្នុងនោះមាន៖ គ្រួសារបុគ្គលិកស៊ីម៉ាក់ចំនួន ១៨នាក់, គ្រួសារនិវត្តន៍ជនស៊ីម៉ាក់ចំនួន០៤នាក់ និងគ្រួសារប្រជាកសិករ ចំនួន ១០នាក់។

2) **ការងារអនុវត្តគំរោង JICA Verification Survey, 2019**

ការិយាល័យស្រាវជ្រាវ/អភិវឌ្ឍកសិកម្ម បានបំពេញការងារ និងទទួលលទ្ធផលដូច មានខាងក្រោម៖

- បានផ្ញើការបញ្ជូនចំណីគោ ទៅឲ្យក្រុមហ៊ុនចិញ្ចឹមគោយកទឹកដោះ MMF ដែលមាន ទីតាំង នៅភូមិអរីយ៍ក្សត្រ ឃុំអរីយ៍ក្សត្រ ស្រុកល្វាអែម ខេត្តកណ្តាល ចំនួន២លើក ក្នុងនោះ លើកទី១ ចំនួន ១០៥ដុំ មានទម្ងន់ចំនួន២៧,៤០៥តោន និងលើកទី២ ចំនួន ១០៨ដុំ មានទម្ងន់២៧តោន សរុបទម្ងន់ស្មើនឹង៥៤,៤០៥តោន។

**៣- ទិសដៅបន្ត:**

- ដំណើរការប្រមូលដុំចំណីគោពីទីវាលមករក្សាទុកនៅកន្លែងមានសុវត្ថិភាព។
- ដំណើរការផ្គត់ផ្គង់ចំណីគោជូន Moo Moo Farm បន្ថែមទៀត។
- សហការណ៍ជាមួយការិយាល័យអភិវឌ្ឍសហគមន៍កសិកម្ម នៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង ដើម្បីបង្កើតសហគមន៍កសិកម្ម នៅមណ្ឌលអភិវឌ្ឍស៊ីម៉ាក់មរតកតេជោ គាស់ក្រឡ។
- សហការជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ លើការងារផ្ទេរ -ប្រគល់គ្រឿងចក្រកសិកម្មនិងឃ្លាំង ជូនប្រធានមណ្ឌលអភិវឌ្ឍសហគមន៍ស៊ីម៉ាក់មរតកតេជោ និងប្រធាន

ការិយាល័យអភិវឌ្ឍសហគមន៍កសិកម្មនៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង គ្រប់គ្រងបណ្តោះអាសន្ន នៅពេលមិនទាន់បង្កើតសហគមន៍កសិកម្មស៊ីម៉ាក់។

- ដំណើរការដាំដំណាំ Sorghum ចំនួន០១ហិកតា សម្រាប់ធ្វើការបង្ហាញដល់សហគមន៍កសិកម្ម។

## ខ-សកម្មភាពការិយាល័យអភិវឌ្ឍន៍ក្រោយបោសសំអាតមីនរួច:

1) ចុះពិនិត្យការងារវិស្វកម្ម ធ្វើផ្លូវនៅភូមិកន្ទួត ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង។
2) ទទួលសិក្ខាកាមអ៊ីរ៉ាក់ទស្សនៈកិច្ច គម្រោងអភិវឌ្ឍក្រោយបោសសំអាតមីនរួច។
3) ចូលរួមបើកវគ្គហ្វឹកហ្វឺនកសិកម្ម ដល់និវត្តជនស៊ីម៉ាក់ ចំនួន៥៣នាក់ នៅCDC ។
4) ចូលរួមជាមួយ JICS ចុះវាយតម្លៃការងារ ធ្វើផ្លូវគម្រោងឆ្នាំ២០១៩។
5) ចូលរួមវគ្គបណ្តុះបណ្តាលកសិកម្មដំណាំស្រូវ ពោតក្រហម និងដំឡូងមី ដល់កសិករចំនួន៣ភូមិ គឺភូមិស្វាយជ្រុំ ភូមិកណ្តាល ភូមិអូរដាំក្រោម ឃុំកំពង់ល្ពៅ ស្រុកសំឡូត ខេត្តបាត់ដំបង សរុបកសិករចំនួន១៨០នាក់។

## ៧-សកម្មភាពនាយកដ្ឋាន:

- ថ្ងៃទី០៥-០៦ ខែមករា ឆ្នាំ២០២០ ចូលរួមបិទរូបភាព ៧ មករា ២០២០ នៅកន្លែងខ្មោចប៉ុល ពត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
- ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ចូលរួមប្រជុំជាមួយអាជ្ញាធរមីន ស្តីពីការរៀបចំទិវាយល់ដឹងពីមីន២៤ គុម្ភៈ ឆ្នាំ២០២០ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ និងកែសម្រួល IMSMA REPORT។
- ថ្ងៃទី០៦-១០ ខែមករា ឆ្នាំ២០២០ ចូលរួមរៀបចំបិទរូបភាព តាំងពិព័ណ៌នៅ សាលពិព័ណ៌ស៊ីម៉ាក់ ភ្នំពេញ។

## ៨-ការលំបាក និងឧបសគ្គ:

ក្នុងខែមករា ឆ្នាំ២០២០នេះ ក្រុមការងារអប់រំមីន បានជួបការលំបាកមានដូចជា៖

- សម្លៀកបំពាក់ ឯកសណ្ឋានស៊ីម៉ាក់ ចាស់ៗពេក មើលទៅមិនសមរម្យ។

## ៩-សំណូមពរ:

ដើម្បីឲ្យការអប់រំការយល់ដឹងពីមីន និងស.ផ.ស កាន់តែមានប្រសិទ្ធភាព ក្រុមការងារអប់រំមីន នៅតាមគោលដៅមួយចំនួន បានធ្វើសំណូមពរដូចជា៖

- ✓ ស្នើសុំសម្ភារៈអប់រំមីនឲ្យបានគ្រប់គ្រាន់
- ✓ ស្នើសុំសម្លៀកបំពាក់(ឯកសណ្ឋានស៊ីម៉ាក់ថ្មី)

- ✓ ស្នើសុំថវិកាបន្ថែម ដើម្បីពង្រីកការងារបណ្តុះបណ្តាលជំនាញអប់រំយល់ដឹងពីមីន ដល់មន្ត្រីនគរបាលជាតិស្ម័គ្រចិត្ត។

## ១០-ផែនការបន្ទាប់:

- ចុះសិក្សា និងជ្រើសរើសមន្ត្រីនគរបាលជាតិ លើខេត្ត៦គឺខេត្តស្ទឹងត្រែង ព្រះវិហារ កំពង់ធំ សៀមរាប ឧត្តរមានជ័យ និងបាត់ដំបង សម្រាប់ជំនួសដំណែងបុគ្គលិកនាយតំណាងគ្រាប់ប្រចាំស្រុក ដែលត្រូវផ្លាស់ប្តូរសមាសសភាព ។
- ចុះជ្រើសរើសមន្ត្រីនគរបាលស្ម័គ្រចិត្តចំនួន១០០នាក់ ធ្វើជាគ្រូបង្គោល សម្រាប់បើកវគ្គ ផ្តល់ជំនាញអប់រំផ្សព្វផ្សាយយល់ដឹងពីមីន/ស.ផ.ស។
- ចូលរួមរៀបចំពិធីអបអរសាទរ ខួបទីវាយល់ដឹងអំពីមីន ២៤ កុម្ភៈ ២០២០ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់

# រូបភាពសកម្មភាព

## MRE & CMAC STAFF ( CBMRR )

















CMAC






CMAC
Danger!! Mines!!




ប្រយ័ត្នគ្រាប់មីន!!
CMAC
Danger!! Mines!!


CMAC
Danger!! Mines!!






តំណាងមីនស្ម័គ្រចិត្ត
ISUZU


















POLICE




CMAC






ACTION CENTRE







# រូបភាពសកម្មភាព

## MRE & CMAC STAFF ( CBURR )


1500





















# រូបភាពសកម្មភាព

## POLICE NETWORK




CMAC
ប្រយ័ត្នគ្រាប់មីន!!
CMAC
Danger!! Mines!!




CMAC
ប្រយ័ត្នគ្រាប់មីន!!
CMAC
Danger!! Mines!!






CMAC








ប្រយ័ត្នគ្រាប់មីន!!
CMAC
Danger!! Mines!!















CMAC


CMAC


CMAC


# រូបភាពសកម្មភាព

# សិក្សាស្រាវជ្រាវ/អភិវឌ្ឍន៍កសិកម្ម




HITACHI










HITACHI











# រូបភាពសកម្មភាព

# ព្រះសង្ឃស្ម័គ្រព្រះទ័យ











អបអរសាទរ
ខួបលើកទី ៤១ នៃទិវាជ័យជម្នះ ៧ មករា (១៩៧៩ - ២០២០)











# រូបភាពសកម្មភាព

# អភិវឌ្ឍក្រោយការបោសសម្អាតមីន







ពិធី
ថ្ងៃទី០៧ ខែមករា ឆ្នាំ២០២០


HITACHI









Constructed under Japan's Grant Aid for Promoting the
July 2019




